**សាលាដំបូងរាជធានីភ្នំពេញ, <u>សាលក្រមលេខ៤៨</u> (ក្រ) ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១**

**ពាក្យគន្លឹះ៖** មនុស្សឃាដគិតទុកជាមុន, ពេលប្រព្រឹត្តមិនបាននៅទីតាំង, អនីតិជន, សវនាការកំបាំងមុខ។

**កាលបរិច្ឆេទ៖** ធ្នូ ២០០៨ (កើតហេតុ), ឃាត់ខ្លួនម្នាក់ (១១ មីនា ២០១០), ឃុំខ្លួន (១៥ មីនា ២០១០), ដីកាសន្និដ្ឋានស្ថាពរ(វិច្ឆិកា២០០៩), ដីកាដំណោះស្រាយ (ធ្នូ ២០០៩), សវនាការ ( មេសា ឆ្នាំ ២០១១) និងសាលក្រម ខែឧសភាឆ្នាំ២០១១។

**អង្គហេតុនិងការសម្រេច៖** ជនរងគ្រោះជាមនុស្សពេញវ័យត្រូវបានរាយការណ៍ថារងរបួស (យប់ម៉ោង១) និង៦ថ្ងៃក្រោយកើតហេតុ ក្នុងឡានឆ្ពោះទៅកាន់មន្ទីរពេទ្យនៅវៀតណាមបានស្លាប់។ សាក្សីបានអះអាងផ្សេងគ្នាថា ជាទង្វើប្លន់ឬគ្រោះថ្នាក់ចរាចរ។ មានរបាយការណ៍ប៉ូលីសចំនួន២ ក៏ប៉ុន្តែមិនមានកំណត់ហេតុ។ មានសាក្សីតែម្នាក់បានឃើញអង្គហេតុ (ជនសង្ស័យពីនាក់ ដែលប្រាប់ថាឲ្យគាត់ចេញពីកន្លែងកើតហេតុ) ក៏ប៉ុន្តែមិនបានបង្ហាញឬចំណាំជនសង្ស័យ។ សាក្សីប្រហែល១០ រូប រួមមានប៉ូលីស បានគ្រាន់តែអះអាងលឺតគ្នា ថាមានមនុស្សមួយក្រុមប្រព្រឹត្ត។ ប៉ូលីសម្នាក់ជាសាក្សីសំខាន់ បានលឺតគ្នាថាមានការសម្លាប់ និងទទួលឈ្មោះជនសង្ស័យពីគេ (គ្មានការសួរដេញដោលបន្ត) និងបានទៅមើលផ្ទះពួកជនសង្ស័យ ដឹងថាពួកគេបានរត់គេចខ្លួន។

ក្នុងថ្ងៃសវនាការ មានតែជនត្រូវចោទម្នាក់បានចូលរួម រីឯជនត្រូវចោទមួយចំនួន (៦រូប) តំណាងដោយមេធាវី។ ក្នុងនោះ មានជនត្រូវចោទម្នាក់មានអាយុ១៥ឆ្នាំ។ ជនត្រូវចោទនោះ និងមេធាវីអះអាងថាអាចជាគ្រោះថ្នាក់ចរាចរ កូនក្តីមិនបានប្រព្រឹត្តិ មានវិមតិសង្ស័យ។ កូនក្តីខ្ញុំមិននៅកន្លែងកើតហេតុ។

ព្រះរាជអាជ្ញាទទួលស្គាល់ថាមានរបាយការណ៍ពីរ (ប្លន់) និងគ្រោះថ្នាក់ចរាចរ និងមិនមានកំណត់ហេតុនៅកន្លែងកើតហេតុ។ នេះជាបញ្ហានៃរបៀបធ្វើការងារ ទោះបីជាយ៉ាងនេះក្តី ទុកជូនលោកចៅក្រមពិចារណាចុះ។

ក្រុមប្រឹក្សាជំនុំជម្រះទទួលស្គាល់ថា ជនរងគ្រោះ ៦ថ្ងៃក្រោយបានស្លាប់។ ...ក្រោយពីកើតហេតុជនត្រូវចោទ ដែលមានឈ្មោះទាំងអស់រត់គេច។ សាក្សីជាសាច់ញាតិជនត្រូវចោទម្នាក់ ទៅសួរសុខទុក្ខម្តាយជនរងគ្រោះ...តិចក្រែងលោមានអ្នកណាមកសរបេសំរួល។ *គឺបញ្ជាក់ពីចេតនារបស់ឈ្មោះ....ដែលទៅចរចាររឿងសំណងជាមួយជនរងគ្រោះ ដូចសាក្សី...បានបញ្ជាក់មែន*។ សាក្សីឈ្មោះ...ឃើញជនរងគ្រោះដួលសន្លប់...ខ្លួនបំរុងចូលទៅជួយ ជនល្មើសស្រែកឲ្យខ្លួនងាកចេញ *បញ្ជាក់ឲ្យឃើញថា ក្រុមជនល្មើសពិត*

*ជាបានប្រព្រឹត្តអំពើប្លន់សម្លាប់ជនរងគ្រោះ ដើម្បីយកទ្រព្យសម្បត្តិជនរងគ្រោះ ហើយអំពើប្លន់នេះ គឺជាបទល្មើសឃាដកម្មគិតទុកជាមុន* (ទំ.១០)។

**សម្រេចៈ ១.** សងរួមគ្នាដល់ជនរងគ្រោះលើជម្ងឺចិត្តនិងការខូចខាត ៧៥០០ ដុល្លា (ទារ២០មឺនដុល្លា-ជំងឺចិត្តនិងថ្លៃព្យាបាល)។ **២.** ជនត្រូវចោទ៦រូប អាយុចន្លោះ ២០ដល់២២ ឆ្នាំដាក់ពន្ធនាគារចំនួន ១៥ឆ្នាំ។ រីឯម្នាក់អាយុ ១៥ឆ្នាំ ដាក់ក្នុងពន្ធនាគារ៧ឆ្នាំ។

**កំណត់សំគាល់ៈ ក.** សំណាងតិចនេះដូចជាតិចតួច។ **ខ.** អង្គហេតុនៅមានមន្ទិលច្រើន ជាពិសេសថាតើជនសង្ស័យបានប្រព្រឹត្តឬមិន។ **គ.** មនុស្សឃាដគិតទុកជាមុន ទាមទារនូវការត្រៀមរៀបចំផែនការប្រព្រឹត្ត ឬពួនស្ទាក់ (មាត្រា៨២នៃក្រមព្រហ្មទណ្ឌឆ្នាំ២០១០ របស់កម្ពុជា)។ ក្នុងឆ្នាំកើតហេតុ២០០៨ ក្រមព្រហ្មទណ្ឌមិនទាន់ចូលជាធរមាន ក៏ប៉ុន្តែឆ្នាំ២០១១ (សវនាការ) ចូលជាធរមានរួចហើយ។ **ឃ.** មនុស្សឃាដគិតទុកជាមុន តម្រូវឲ្យមានចេតនាឲ្យស្លាប់ ក្នុងរឿងនេះ ជនរងគ្រោះមិនស្លាប់ភ្លាមទេ។ **ង.** ទង្វើបង្កឲ្យស្លាប់អាចជាមនុស្សឃាតមានចេតនា ឬអចេតនា ទោសធ្ងន់ឬស្រាលអាស្រ័យទៅតាមប្រភេទបទល្មើស។ **ច.** គិតពីថ្ងៃកើតហេតុ ដល់ថ្ងៃសវនាការ មានរយៈពេល២ឆ្នាំ៧ ខែ។

**សំណួរអាចលើកឡើងៈ** ១. តើការបង្ករបួសស្នាម ដែលជនសង្ស័យដឹងថា វាទំនងជានឹងធ្វើឲ្យជនរងគ្រោះស្លាប់ បង្ហាញអំពីចេតនា? **២.** អ្វីទៅជាភាពខុសគ្នារវាងបទមនុស្សឃាដគិតទុកជាមុន, ឃាតកម្ម (ចេតនាសម្លាប់ភ្លាមៗ) និងមនុស្សឃាតដោយអចេតនា។